CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី 25 ខែកុម្ភៈ ឆ្នាំ 2021
ទំនាក់ទំនង ៖ ហ្គារី ជេ អ៊ែនឌឺសុន (Gary J. Anderson) រដ្ឋអាជ្ញារង ក្រុងចំបង,
Gary.Anderson@longbeach.gov

សម្រាប់ការផ្សព្វផ្សាយភ្លាមៗ

# ចៅក្រម បដិសេធ ការដាក់កំហិត ជាបឋម លើការទូទាត់ប្រាក់បុព្វលាភ របស់ក្រុង សម្រាប់បទបញ្ជា ស្តីពីពលករវិស័យលក់រាយស្បៀងអាហារ

ឡុងប៊ិច, CA - សាលាក្រុងឡុងប៊ិច មានក្តីសោមនស្ស ដែល អូទិស រាយ (Otis Wright) ចៅក្រមសាលាក្តីមណ្ឌល បានបដិសេធ វិធានការ របស់សមាគមវិស័យលក់រាយស្បៀងអាហារ កាលីហ្វ័រញ៉ា សម្រាប់ការដាក់កំហិត ជាបឋម ។ នេះអនុញ្ញាតឱ្យ ការទូទាត់ប្រាក់បុព្វលាភ របស់ឡុងប៊ិច សម្រាប់បទបញ្ជា ស្តីពីពលករវិស័យលក់រាយស្បៀងអាហារ នៅដំណើរការបាន ហើយធានាថា ហាងលក់រាយស្បៀងអាហារផ្តល់សំណងទូទាត់ ប្រកបដោយយុត្តិធម៌ ដោយទទួលស្គាល់ពីហានិភ័យ ដែលពលករប្រឈម ពេលបន្តផ្តល់សេវាសំខាន់ៗ របស់ពួកគេ ក្នុងពេលមានបញ្ហាឆ្លងរាតត្បាត COVID-19 ជាសាកល ។

ឆាល ផាកឃីន (Charles Parkin) រដ្ឋអាជ្ញា ក្រុងឡុងប៊ិច បានលើកឡើងថា «យើងខ្ញុំមានក្តីសោមនស្សណាស់ ដែលចៅក្រម រាយ (Wright) បានឯកភាព នឹងជំហរ របស់សាលាក្រុង ពាក់ព័ន្ធនឹងតួនាទីសំខាន់ ដែលពលករហាងលក់រាយស្បៀងអាហារបំពេញ នៅក្នុងសហគមន៍ នៅពេលមាន ជំងឺឆ្លងរាតត្បាត ជាសាកល និង គ្រោះអាសន្នជាតិនេះ ។» «គាត់បានស្តាប់ យ៉ាងច្បាស់លាស់ អំពីការតវ៉ា ផ្លូវច្បាប់ ដោយប្រុងប្រយ័ត្ន និងមានការគិតគូរត្រឹមត្រូវ ហើយត្រូវបានបញ្ជាក់ បានយ៉ាងល្អ នៅក្នុងច្បាប់រឿងក្តីពាក់ព័ន្ធអំពីបញ្ហានេះ, និងនៅទីបញ្ចប់ ទាញសេចក្តីសន្និដ្ឋានថា គ្មានមូលដ្ឋាន ដែលត្រូវបញ្ឈប់សាលាក្រុង មិនឱ្យអនុវត្ត បទបញ្ជា «ទូទាត់វីរជន» របស់យើងនោះទេ ។»

សម្រាប់ព័ត៌មានចុងក្រោយបំផុត អំពី COVID-19 ដែលមានសេចក្តីលំអិត អំពីសកម្មភាពទាំងអស់ របស់សាលាក្រុងឡុងប៊ិច ក្នុងការរក្សាសុវត្ថិភាព របស់ប្រជាពលរដ្ឋរបស់យើង សូមចូលទៅ long-beach.gov/COVID19 ហើយតាម @LongBeachCity នៅលើ Facebook, Twitter និង Instagram ។

# # #